# ការក្រសោបយកភាពតានតឹង៖ សិទ្ធិមនុស្ស ៣៦៥

ជារឿយៗបំផុត វាមានប្រយោជន៍ក្នុងការពិនិត្យមួយដែលមានរយៈពេលវែង ដើម្បីទទួលបានទស្សនទានជាម៉ែត្រវាស់ប្រវែងដប់ឆ្នាំ ដើម្បីពិនិត្យមើលភាពខុសគ្នារវាងស្ថានភាពពីមុន និងស្ថានភាពបច្ចុប្បន្ន។ ថ្ងៃនេះខ្ញុំរីករាយដោយឃើញកម្រិតនៃការយល់ដឹងដែលបានស្តែងចេញ ទាំងការទាមយុត្តិធម៌ ទាំងការគោរពពីប្រជាជនធម្មតាមានការកើនឡើង ក៏ដូចជាការប្រកាសដោយរដ្ឋាភិបាលថា ការទាមទារទាំងនេះ កំពុងត្រូវបានគេស្តាប់ ហើយថាកំណែទម្រង់នឹងធ្វើនៅពេលក្រោយ។ យើងធ្វើជាសាក្សីនូវកំណែទម្រង់ដូចនេះ ដែលបាននិងកំពុងបន្តធ្វើយ៉ាងខ្លាំងក្លាក្នុងវិស័យអប់រំ ជាតួយ៉ាង បើទោះជាជួបប្រទះឧបសគ្គច្រើនហួសប្រមាណក្តី។ ដោយគ្មានការប្រកាន់បែងចែក ជនគ្រប់រូបដែលខ្ញុំបានជួប ដែលពួកគាត់នៅទីនេះកាលពីដប់ឆ្នាំមុន ហើយគាត់នៅទីនេះនៅឡើយ ឬនៅទីនេះនៅថ្ងៃនេះ ពួកគាត់សំដែងការស្ងប់ស្ងែងចំពោះការរីកចម្រើនដែលពួកគាត់ឃើញ។ ជាការពិតណាស់ ប្រទេសមួយដែលអាចផលិតអង្ករល្អបំផុតនៅលើពិភពលោក និងទាក់ទាញអ្នកវិនិយោគទុន និងភ្ញៀវទេសចរណ៍បានយ៉ាងច្រើនសន្ធឹកសន្ធាប់ ក្នុងសន្ទុះមួយដែលយើងមើលឃើញនៅទីនេះ គឺជាការធ្វើការងារមួយដែលត្រឹមត្រូវ។

ទោះបីជាមានចន្លោះខ្វះខាតខ្លះក្តី ក៏ច្បាប់គ្រឹះទាំងបីស្តីពីប្រព័ន្ធតុលាការ បង្កើតជាផែនគ្រឹះមួយចំនួនដ៏រឹងមាំសម្រាប់ការគ្រប់គ្រងប្រព័ន្ធតុលាការឲ្យកាន់តែប្រសើរឡើងថែមទៀត។ ទន្ទឹមនេះដែរ វិធានការសំខាន់ៗមួយចំនួនបាននិងកំពុងចាត់ ក្នុងវិស័យប្រឆាំងអំពើពុករលួយ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងវិស័យជាច្រើនផ្សេងទៀត។

ទោះជាដូច្នេះក្តី ការរីកចម្រើនទាំងនេះ ក៏មានស្រមោលគ្រប់ពីលើដោយឧប្បត្តិហេតុជាច្រើនដែលបង្ហាញពីបុព្វហេតុដែលវិស័យទាំងនេះ ត្រូវការឲ្យមានការធ្វើកំណែទម្រង់ដំបូងគេ។ ភាពចម្រូងចម្រាសជុំវិញឯករាជ្យភាពនៃតុលាការ នៅតែជាបញ្ហាក្តៅដូចសព្វដង។ មានអ្នកដែលនឹងចំណាយពេលវេលានៅក្នុងឱកាសនៃទិវាសិទ្ធិមនុស្ស ធ្វើការតស៊ូពុះពារ ដើម្បីការពារដីធ្លីរបស់ខ្លួន ការសុំសិទ្ធិជ្រកកោន ការរើបម្រះចេញពីអំពើហិង្សា ឬការគ្រាន់តែបង្ហាញពីការទាមទាររបស់ខ្លួន។ ប្រសិនជាគេត្រូវតែប្រថុយជីវិត ឬសេរីភាពរបស់ខ្លួនដើម្បីធ្វើការងារណាមួយក្នុងនោះ អញ្ចឹងវាពិតជាមានអ្វីដែលមិនត្រឹមត្រូវហើយ។ ការទទួលបានឡើងវិញនូវជំនឿទុកចិត្តពីសាធារណៈជន ពិតណាស់គឺជាតម្រូវឲ្យមានការធ្វើកំណែទម្រង់មួយខ្លាំងក្លា ដូចបានឃើញនៅក្នុងវិស័យអប់រំ ដូច្នេះដែរ។

ប្រធានបទពិភពលោកនៃទិវាសិទ្ធិមនុស្សនៅឆ្នាំនេះ គឺ ″សិទ្ធិមនុស្ស ៣៦៥″ ។ វារំលឹកយើងរាល់គ្នាថាសិទ្ធិមនុស្សសំខាន់ចំពោះមនុស្សគ្រប់រូប រៀងរាល់ថ្ងៃនៃឆ្នាំ។ វាគួរតែជាថ្ងៃមួយសម្រាប់មនុស្សគ្រប់រូប មកជួបជុំគ្នា ដើម្បីធ្វើការបូកសរុបសមិទ្ធផលដែលសម្រេចបាន និងបញ្ហាប្រឈមផ្សេងៗ និងដើម្បីបញ្ជាក់ជាថ្មី អំពី

តម្លៃនិងការប្តេជ្ញាចិត្តរបស់យើង ដើម្បីបោះជំហានទៅមុខ នៅឆ្នាំថ្មីដែលនឹងមកដល់។ ដោយមានឧបសគ្គមួយចំនួនបានកើតមានមុខថ្ងៃនេះ នៅខេត្តមួយចំនួន បាននាំឲ្យយើងមានចម្ងល់អំពីការរីកចម្រើនពិតប្រាកដសម្រេចបានប៉ុណ្ណាទៅ ប្រសិនជាព្រឹត្តិការណ៍ភាគច្រើន មិនបានដំណើរការដោយសន្តិវិធីទេនោះ ដែលជាអកុសល ករណីនេះទំនងអាចមាន (នៅពេលកំពុងសរសេរនេះ)។

នៅលើឆាកអន្តរជាតិ ពិភាក្សាអំពីវិសាលភាព និងដែនកំណត់នៃសិទ្ធិមនុស្ស បានអនុញ្ញាតឲ្យមានទស្សនៈប្រកាន់ខ្ជាប់រួមគ្នា ដូចជា ទស្សនៈអំពីវប្បធម៌ ប្រពៃណី អធិបតេយ្យជាតិ និងទស្សនៈថ្មីៗដែលទើបលេចឡើង ដូចជាទស្សនៈអំពីការគំរាមកំហែងសន្តិសុខដោយអំពើភេរវកម្ម ដើម្បីទទួលបានប្រយោជន៍ពីការជជែកពិភាក្សា និងការជជែកពិភាក្សាជំទាស់។ ទស្សនៈភាគច្រើនក្នុងនោះ បានដាក់ទៅក្នុងដំណើរការនេះបង្ហាញថា មធ្យោបាយដែលល្អបំផុត ដើម្បីភ្ជាប់គម្លាតនោះគឺតាមរយៈការសន្ទនា និងការបើកចំហថែមទៀតមិនតិចនោះទេ។ នៅក្នុងស្មារតីនេះ មូលហេតុដែលថាហេតុអ្វីបានជាដំណើរការនៃការធ្វើកំណែទម្រង់ប្រព័ន្ធតុលាការនៅទីនេះ នៅប្រទេសកម្ពុជា មិនបានបន្ថយការអំពាវឲ្យមានឯករាជ្យភាព ដែលសង្ឃឹមថានឹងត្រូវបានពិភាក្សាស៊ីជម្រៅនៅក្នុងសន្និសិទមួយដែលនឹងប្រារព្ធធ្វើនៅសប្តាហ៍ក្រោយនេះ ស្តីពីការផ្សព្វផ្សាយច្បាប់គ្រឹះទាំងបីស្តីពីប្រព័ន្ធតុលាការ។

ទន្ទឹមនឹងមានការសន្ទនាត្រង់ៗរវាងទស្សនៈជំទាស់នឹងមានភាពតានតឹង តាមរយៈនិយមន័យនេះ ការក្រសោបយកភាពតានតឹង គឺជាជំហានដំបូងឆ្ពោះទៅកាន់ការដោះស្រាយបុព្វហេតុរបស់វា។ ជាការពិតណាស់ ប្រហែលជាយើងធ្វើជាសាក្សីចំពោះវិធានការដំបូងដែលបាននិងកំពុងចាត់នេះ។ កាន់តែឆាប់ កាន់តែល្អ ព្រោះថា ការរំពឹងទុករបស់ប្រជាជននៅក្នុងសេដ្ឋកិច្ចមួយមានល្បឿនខ្ពស់ អាចកើនឡើងជាមួយនឹងពេលវេលា អញ្ចឹងទេ ភាពតានតឹងនៅក្នុងសង្គមក៏មិនខុសគ្នាដែរ។ សារនៅឆ្នាំនេះ ឧទ្ទិសដល់មនុស្សគ្រប់រូប នៅគ្រប់ទិសទី នៅគ្រប់ទស្សនៈផ្សេងៗគ្នា។ សិទ្ធិមនុស្សជារបស់យើងគ្រប់គ្នា ៣៦៥ ថ្ងៃ ក្នុងមួយឆ្នាំ។

លោកស្រី វ៉ាន-ហ៊ី លី
តំណាងការិយាល័យ OHCHR ប្រចាំកម្ពុជា

---